**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៧៩)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ២ ៤៩៤នាក់ នៃសហគ្រាសទាំង៣៩ នៃវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលសហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ១២០ ០០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦០ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះ ទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅសហគ្រាសទាំង៣៩ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួនទៅរដ្ឋបាលសហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មករសហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ អង្គារ ៥រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០២២

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

### ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២

### បញ្ជីឈ្មោះ សហគ្រាស ក្នុងវិស័យទេសចរណ៍
### ចំនួន ៣៩ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះសហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| វិស័យទេសចរណ៍ | | 39 |
| 1 | សណ្ឋាគារ រ៉េស៊ីដង់ សុខាភ្នំពេញ | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ថាលាស | ភ្នំពេញ |
| 3 | ក្រុមហ៊ុន សិប្បករអង្គរ ភ្នំពេញ | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ឌីថាមត្រាវែល ខេមបូឌា | ភ្នំពេញ |
| 5 | ក្រុមហ៊ុន រ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 6 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 7 | ភោជនីយដ្ឋាន វិរតន៍ | សៀមរាប |
| 8 | ក្រុមហ៊ុន បា ឡឺ កូដ ត្រេឌីង | សៀមរាប |
| 9 | ផ្ទះសំណាក់ សាតូអង្គ | សៀមរាប |
| 10 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 11 | សណ្ឋាគារសុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 12 | សណ្ឋាគារ បាយ័ន អេរ៉ា ហូថែល ឧបភើរេសិន | សៀមរាប |
| 13 | ក្រុមហ៊ុន កាឡាស ខម (ខេមបូឌា) ភីធីអ៊ី អិលធីឌី (សណ្ឋាគារ អង្គរ អេរ៉ា) | សៀមរាប |
| 14 | សណ្ឋាគារ អង្គរមិរ៉ាខល រីហ្សត និង ស្ប៉ា | សៀមរាប |
| 15 | សណ្ឋាគារសោមាទេវីអង្គររីសត & ស្ប៉ា | សៀមរាប |
| 16 | ក្រុមហ៊ុន អេប៉ិច ខេមបូឌា ត្រាវ៉ែល សែរវីស | សៀមរាប |
| 17 | សណ្ឋាគារ យើងដុម អង្គរ | សៀមរាប |

| ល.រ | ឈ្មោះសហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 18 | ភោជនីយដ្ឋាន នារីខ្មែរ | សៀមរាប |
| 19 | ក្រុមហ៊ុន ជាតិថាតា អង្គរ | សៀមរាប |
| 20 | សណ្ឋាគារប៉ាវ៉ាឌីសអង្គរវីឡា | សៀមរាប |
| 21 | សណ្ឋាគារ សារ៉េរីសត និង ស្ប៉ា | សៀមរាប |
| 22 | ក្រុមហ៊ុន ដំរីអង្គរ ខូ អិលធីឌី | សៀមរាប |
| 23 | ក្រុមហ៊ុន ម៉េម៉រ អង្គរ | សៀមរាប |
| 24 | សណ្ឋាគារ សិន្ធា មុន្នី | សៀមរាប |
| 25 | សណ្ឋាគារគោព្រៃ | សៀមរាប |
| 26 | សណ្ឋាគារតាព្រហ្ម | សៀមរាប |
| 27 | ក្រុមហ៊ុន អេមព្រីស អង្គរ | សៀមរាប |
| 28 | ក្រុមហ៊ុន អេរីតាស ॥ | សៀមរាប |
| 29 | ភោជនីយដ្ឋានចាន់រីទ្រី | សៀមរាប |
| 30 | សណ្ឋាគារ លីនាយាអង្គរ រីសត និងស្ប៉ា | សៀមរាប |
| 31 | ក្រុមហ៊ុន អញ្ជលី បាយ ស៊ីផុន | សៀមរាប |
| 32 | ក្រុមហ៊ុន ខ្មែរអង្គរហូថែលកូអិលធីឌី | សៀមរាប |
| 33 | សណ្ឋាគារទ្រីឡាញ អឺបេន រីហ្សត | សៀមរាប |
| 34 | ភោជនីយដ្ឋានសុខៈរីវើ | សៀមរាប |
| 35 | ភោជនីយដ្ឋានសុខៈរីវើរីវើឡោញ | សៀមរាប |
| 36 | ក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស | សៀមរាប |
| 37 | សណ្ឋាគារសុខៈប៊ូទិក | សៀមរាប |
| 38 | ក្រុមហ៊ុន អឺបៅអេស៊ា | សៀមរាប |
| 39 | ក្រុមហ៊ុន ថ្មរូង ឌីវេឡុបមេន | ព្រះសីហនុ |